ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ២៧៧ អយក.សលាន

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៧

# សេចក្តីណែនាំស្តីពី
# ការប្រមូល និងបំពេញ តារាងជំរឿនស្ថិតិសាលារៀនចំណេះទូទៅឯកជន និងមត្តេយ្យសិក្សាសហគមន៍ប្រចាំឆ្នាំសិក្សា ២០១៧-២០១៨

ក្នុងគោលបំណងធ្វើឱ្យមានភាពសុក្រឹតក្នុងការប្រមូលទិន្នន័យអប់រំគ្រប់ប្រភេទពីសាលារៀនចំណេះទូទៅឯកជនគ្រប់ភូមិសិក្សា និងមត្តេយ្យសិក្សាសហគមន៍ សម្រាប់ឆ្នាំសិក្សា២០១៧-២០១៨ ក្រសួងអប់រំ យុវជន និងកីឡា សូមធ្វើការណែនាំដូចខាងក្រោមៈ

**១-នាយក នាយិកាសាលារៀនឯកជន និងគណៈគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ទាំងអស់**

លោកនាយក លោកស្រីនាយិកាសាលារៀន និងគណៈគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ប្រមូលយកស្ថិតិសិស្សជាក់ស្តែងក្នុងថ្នាក់ដែលគ្រូទទួលបន្ទុកថ្នាក់មកបូកសរុប ហើយកត់ត្រាចូលក្នុងចំណុចទី២.(ក) ទី២.(ខ) ទី២.(គ) និងទី៣ នៃតារាងជំរឿនស្ថិតិសាលារៀន និងមត្តេយ្យសិក្សាសហគមន៍ប្រចាំឆ្នាំ (ដូចមានជូនភ្ជាប់ )។ លទ្ធផលស្ថិតិសិស្សសរុបក្នុងតារាងទី២.(ក) ជាស្ថិតិបវេសនកាលឆ្នាំសិក្សា២០១៧-២០១៨ របស់សាលារៀន។ នាយក នាយិកាសាលារៀន និងគណៈគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ត្រូវបំពេញទិន្នន័យ ព័ត៌មានឱ្យបានសព្វគ្រប់ទាំងអស់ និងត្រូវពិនិត្យផ្ទៀងផ្ទាត់ឱ្យបានត្រឹមត្រូវទើបផ្ញើត្រឡប់ទៅការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌវិញឱ្យបានមុន ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៧។ ចំពោះស្ថិតិបវេសនកាលនេះ នាយក នាយិកាសាលារៀន និងគណៈគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ត្រូវកត់ត្រាលើក្តារខៀនស្ថិតិក្នុងទីចាត់ការដើម្បីប្រើប្រាស់ជាទូទៅឱ្យបានឯកភាពគ្នា។

**២-ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ**

មានភារកិច្ចក្នុងការចុះសម្របសម្រួលការងារបំពេញតារាងជំរឿនស្ថិតិសាលារៀនតាមគ្រប់ភូមិសិក្សា និងមត្តេយ្យសិក្សាសហគមន៍ និងពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យក្នុងតារាងជំរឿនស្ថិតិសាលារៀន និងមត្តេយ្យសិក្សាសហគមន៍ប្រចាំឆ្នាំទាំងអស់ក្នុងក្រុង ស្រុក ខណ្ឌ របស់ខ្លួន។ ជាមួយគ្នានោះដែរ ការិយាល័យអប់រំយុវជន និងកីឡា ក្រុង ស្រុក ខណ្ឌត្រូវធ្វើការបូកសរុបស្ថិតិសង្ខេបដែលទទួលបានដើម្បីបំពេញរបាយការណ៍បវេសនកាល ឬដើមឆ្នាំសិក្សា២០១៧-២០១៨ និងផ្ញើទៅមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រឹមថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ២០១៧។

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទៈ (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារៈ (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែលៈ info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

**៣-មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត**

ត្រូវធ្វើជាបន្តបន្ទាប់នូវតារាងជំរឿនស្ថិតិសាលារៀន និងមត្តេយ្យសិក្សាសហគមន៍ប្រចាំឆ្នាំ ដែលទទួលបាន និងផ្ទៀងផ្ទាត់ត្រឹមត្រូវ (ដោយមិនរង់ចាំឱ្យបានគ្រប់សាលារៀន និងមត្តេយ្យសិក្សាសហគមន៍) ទៅក្រសួងអប់រំ យុវជន និងកីឡា (នាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ) ឱ្យបានត្រឹម ថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ២០១៧។ មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ត្រូវបញ្ចូល និងពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យឱ្យត្រឹមត្រូវគ្រប់ចំណុចនិងគ្រប់សាលារៀន និងមត្តេយ្យសិក្សាសហគមន៍ រួចបញ្ជូនទៅក្រសួងអប់រំ យុវជន និងកីឡា (នាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ) យ៉ាងយឺតបំផុតត្រឹម ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧។

ក្រសួងអប់រំ យុវជន និងកីឡាសង្ឃឹមថា លោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ប្រធានការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ និងនាយក នាយិកាសាលារៀនទាំងអស់ នឹងខិតខំជំរុញយន្តការនៃការបំពេញនិងប្រមូលតារាងជំរឿនស្ថិតិសាលារៀនចំណេះទូទៅឯកជន និងមត្តេយ្យសិក្សាសហគមន៍ ប្រចាំឆ្នាំសិក្សា ២០១៧-២០១៨ នេះបានត្រឹមត្រូវល្អ ពិតប្រាកដ ទៀងទាត់ គ្រប់គ្រាន់ និងទាន់ពេលវេលា ជាក់ជាមិនខាន។

សូមលោក លោកស្រីទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ

**ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**រដ្ឋលេខាធិការ**

**ណាត ប៊ុនរឿន**

**ចម្លងជូន:**

- អគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ
- អគ្គនាយកដ្ឋានអប់រំ
- អង្គភាព នាយកដ្ឋានពាក់ព័ន្ធ
  "ដើម្បីជូនជ្រាបជាព័ត៌មាន-និងជួយសហការ"
- ឯកសារ-កាលប្បវត្តិ